**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តឧត្តរមានជ័យ**
លេខ.០០៤...ស.ល..ក.ខ.ជ

# សេចក្តីសម្រេច
## ស្តីពី
## ការទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ របស់ក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ អាណត្តិទី ២ , (២០១៤-២០១៩)

## ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- បានឃើញព្រះរាជក្រមលេខ នស/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុម ប្រឹក្សាខណ្ឌ។
- បានឃើញប្រកាសលេខ ៤២៧៥ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃស្តីពីរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។
- យោងលិខិតជូនដំណឹង១៤៧ សជណ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅក្នុង ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុងក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។
- យោងលិខិតលេខ ២៤៨ សជណ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១១ របស់ក្រសួងមហាផ្ទៃ ស្តីពីការ រៀបចំសមាសភាពមុខតំណែងមួយចំនួននៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ នៅ ក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/៦៦១ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ ។
- យោងស្មារតីអង្គប្រជុំរបស់ គណៈអភិបាលខេត្ត ស្តីពីការជ្រើសរើស សមាសភាពជាប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត នាថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤
- យោងស្មារតីអង្គប្រជុំវិសាមញ្ញលើកទី២ អាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្ត នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤

# សម្រេច

**ប្រការ១.-**

ត្រូវបានទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ អាណត្តិទី២ ដែលមានរាយនាមដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **សួន សាឌុន** | សមាជិកក្រុមប្រឹក្សាខេត្ត | ប្រធាន |
| ២-លោកជំទាវ | **ផុន ស្រីមុំ** | សមាជិកក្រុមប្រឹក្សាខេត្ត | អនុប្រធាន |
| ៣-លោកស្រី | **ឯក សុវណ្ណតារៈ** | អភិបាលរងខេត្ត | អនុប្រធាន |
| ៤-លោក | **លាង ហ៊ីន** | អនុប្រធានមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទាខេត្ត | អនុប្រធាន |
| ៥-លោក | **ឯក សុតារ៉ុ** | ប្រធានមន្ទីរកិច្ចការនារីខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៦-លោកស្រី | **មិន ធារី** | នាយករងរដ្ឋបាលសាលាខេត្ត | សមាជិក |
| ៧-លោក | **សួរ ម៉ារីណា** | ប្រធានមន្ទីរផែនការខេត្ត | សមាជិក |
| ៨-លោកស្រី | **ធិននី មុន្នីរស្មី** | ប្រធានមន្ទីរទេសចរណ៍ខេត្ត | សមាជិក |
| ៩-លោក | **សរ សៀងហៀង** | ប្រធានសាខាកាកបាទក្រហមកម្ពុជា | សមាជិក |
| ១០-លោក | **ឈឹម សុវណ្ណា** | អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | សមាជិក |
| ១១-លោកស្រី | **ឆេង ហឿង** | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | សមាជិក |
| ១២-លោក | **ហៀង ហ៊ី** | អនុប្រធានមន្ទីរធម្មការ និងសាសនាខេត្ត | សមាជិក |
| ១៣-លោក | **ហៀប ឌុនណារិទ្ធិ** | នាយកស្តីទីទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| ១៤-លោក | **លុក គឹមលាន** | នាយកស្តីទីទីចាត់ការរដ្ឋបាលសាលាខេត្ត | សមាជិក |
| ១៥-លោក | **ថូ ចោ** | នាយកស្តីទីទីចាត់ការអន្តរវិស័យ | សមាជិក |
| ១៦-លោក | **អាន់ សំអាត** | នាយកស្តីទីទីចាត់ការហិរញ្ញវត្ថុខេត្ត | សមាជិក |
| ១៧-លោក | **លៀត លីន** | នាយកស្តីទីទីចាត់ការផែនការនិងវិនិយោគ | សមាជិក |
| ១៨-លោក | **លាំ ម៉ូលី** | នាយកការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃ ស្នងការដ្ឋាននគរបាលខេត្ត | សមាជិក |
| ១៩-លោក | **ស្វាយ ហ៊ី** | ប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ | សមាជិក |
| ២០-លោកស្រី | **អ៊ុន ច័ន្ទដេលី** | ប្រធានកម្មវិធីអាហារូបត្ថម្ភ នៃមន្ទីរសុខាភិបាលខេត្ត | សមាជិក |
| ២១-លោក | **ប៉ែន សក្តិពិសិដ្ឋ** | ប្រធានការិយាល័យនីតិកម្មកសិកម្ម នៃមន្ទីរកសិកម្មខេត្ត | សមាជិក |
| ២២-លោក | **ហ៊ីង សារិទ្ធិ** | ប្រធានការិយាល័យភាពយន្ត នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត | សមាជិក |
| ២៣-កញ្ញា | **ម៉ុន ផាឌី** | អនុប្រធានការិយាល័យមធ្យម នៃមន្ទីរអប់រំ | សមាជិក |
| ២៤-កញ្ញា | **សោន សារី** | សមាជិកគណៈកម្មាធិការសមាគមក្រុមប្រឹក្សាឃុំសង្កាត់ | សមាជិក |

**ប្រការ២.-**

តួនាទីនិងរបៀបរបបការងាររបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ត្រូវបានអនុវត្តស្រប ទៅតាមប្រកាសលេខ៤២៧៥ប្រ.ក ចុះថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០០៩ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃស្តីពីរៀបចំនិងប្រព្រឹត្ត

ទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និង យោងលិខិតជូនដំណឹង១៤៧ សជណ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះ យោបល់កិច្ចការស្ត្រីនិងកុមារ២០០៩ របស់ក្រសួងមហាផ្ទៃស្តីពីរៀបចំនិងប្រព្រឹត្តទៅនៃ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

**ប្រការ៣.~**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារ ផ្ទុយពី**សេចក្តីសម្រេចនេះ** ត្រូវទុកជានិរាករណ៍។

**ប្រការ៤.~**

គណៈអភិបាលខេត្ត នាយករដ្ឋបាលខេត្ត ប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត ទីចាត់ការចំណុះរចនាសម្ព័ន្ធសាលាខេត្ត និងសាមីខ្លួន ដែលមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវអនុវត្ត**សេចក្តីសម្រេចនេះ** ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧត្តរមានជ័យ ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៤

**ប្រធានក្រុមប្រឹក្សាខេត្ត**

យឹម_ធិន

**ចម្លងជូន**

- ក្រសួងមហាផ្ទៃ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- លេខធិការដ្ឋានគជអប
- ដើម្បីគោរពជូនជ្រាប
- ដូចក្នុងប្រការ៤ ដើម្បីអនុវត្ត
- ឯកសារកាលប្បវត្តិ